00271185

**Declassified to Public**
**06 September 2012**

E2/15

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 16 / 01 / 2009
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Ang

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ឆ្នាំ ២០០៧/អវតក/អជសដ
Case File/Dossier N° 001/18-07-2007/ECCC/TC

| | |
|---|---|
| ចំពោះមុខ | ចៅក្រម និល ណុន ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម ធួ មណី |
| កាលបរិច្ឆេទ | ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៩ |
| ប្រភេទឯកសារ | សម្ងាត់ |

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 16 / 01 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Ang

## សេចក្តីសម្រេចទទួលស្គាល់មេធាវី Pierre Olivier SUR

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

**ជនជាប់ចោទ**
កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
គង់ ពិសី
ហុង គីមសួន

**មេធាវីជនជាប់ចោទ**
ការ សាវុត្ថ
Fronçois ROUX

001/18-07-2007/ECCC/TC

E2/19

យុង ផានិត

គីម ម៉េងឃី

ម៉ុច សុវណ្ណារី

Silke STUDZINSKY

Martine JACQUIN

Philippe CANNONE

ទី ស្រីនណា

Pierre Olivier SUR

អង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")

បានឃើញសំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសដ ដែលមានជនជាប់ចោទឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ "**ឌុច**" ភេទ ប្រុស ជនជាតិ ខ្មែរ កើតនៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៤២ នៅភូមិ ពៅវើយ ឃុំ ពាមបាង ស្រុក ស្ទោង ខេត្តកំពង់ធំ ។

**បានឃើញ** ឈ្មោះ តូច មុនិន្ទ, ជុំ នៅ, កាន់ សុន្ទរ៉ា, ជ្រាំង សំអ៊ាន, គង់ ទេស, រស់ មេន បានដាក់ពាក្យប្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយកាលពីថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៨ និង ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៨ បានជ្រើសរើសមេធាវី Pierre Olivier SUR ជាមេធាវីអន្តរជាតិ ដែលបានទទួលការយល់ព្រមត្រឹមត្រូវរួចហើយក្នុងបញ្ជីមេធាវីដែលមានបំណងតំណាងជនរងគ្រោះនៅ ចំពោះមុខ អ.វ.ត.ក ជាមេធាវីរបស់ខ្លួន ។ លោកមេធាវី Pierre Olivier SUR ក៏បានយល់ព្រមនូវការស្នើសុំពីងពាក់នេះកាលពីថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៨ និង ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៨ ។

**ដោយត្រូវបាន** ជូនដំណឹងនៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៩ ដោយក្រឡាបញ្ជីការិយាល័យសហចៅក្រមស៊ើបអង្កេតដែលតាមរយៈនេះដើមបណ្ដឹងរដ្ឋប្បវេណីខាងលើបានប្រគល់សិទ្ធិដល់មេធាវី Pierre Olivier SUR ជាមេធាវីតំណាងដោយអាណត្តិរបស់ពួកគេ។

**បានឃើញ** ពាក្យសុំទទួលស្គាល់ មេធាវី Pierre Olivier SUR ជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលមានឈ្មោះដូចខាងលើ នៅក្នុងដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ។

001/18-07-2007/ECCC/TC

E2/15

# ហេតុដូច្នេះអង្គជំនុំជម្រះសាលាដំបូងសម្រេច

១. **ទទួលស្គាល់** លោកមេធាវី Pierre Olivier SUR ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលមានឈ្មោះដូចខាងលើក្នុងគោលបំណងដើម្បីចូលរួមដំណើរការនីតិវិធី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងរបស់ អ.វ.ត.ក ។

២. **កត់សំគាល់ថា** មេធាវីដែលបានទទួលស្គាល់រួចហើយមានសិទ្ធិនិងកាតព្វកិច្ចជាអាទិ ៖

ក. **ការចូលរួមក្នុងដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះសាលាដំបូង** ៖ លោក/លោកស្រីត្រូវបានអនុញ្ញាតឲ្យតំណាងកូនក្តីរបស់ខ្លួន នៅក្នុងអំឡុងពេលដែលពួកគេចូលរួមក្នុងដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដូចមានចែងក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ។

ខ. **ការពិនិត្យពិគ្រោះសំណុំរឿង៖** លោក/លោកស្រី មានសិទ្ធិពិនិត្យមើល និងថតចម្លងឯកសារពីសំណុំរឿងស៊ើបសួរច្បាប់ដើមណា ដែលកូនក្តីរបស់លោក/លោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណីតាមរបៀបថតចម្លងជាក្រដាស ឬតាមបែបអេឡិចត្រូនិក នៅក្នុងពេលម៉ោងធ្វើការ និងដោយគោរពទៅតាមលក្ខខណ្ឌតម្រូវនៃកិច្ចដំណើរការល្អរបស់ អ.វ.ត.ក ។ ការពិនិត្យមើលសំណុំរឿងនេះអាចរៀបចំដោយមានជំនួយរបស់អង្គភាពជនរងគ្រោះ ឬមន្ត្រីគ្រប់គ្រងសំណុំរឿង ប៉ុន្តែត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជីមានសមត្ថកិច្ច ។ លោក/លោកស្រី អាចថតចម្លង ឬស្នើសុំច្បាប់ថតចម្លងឯកសារដែលមាននៅក្នុងសំណុំរឿងតាមចំនួនសមរម្យ និងយកឯកសារទាំងនោះទៅពិភាក្សាជាមួយកូនក្តីរបស់លោក/លោកស្រី ប៉ុន្តែលោក/លោកស្រី មិនអាចប្រគល់ឯកសារថតចម្លងទាំងនោះទៅឲ្យកូនក្តីរបស់ លោក/ លោកស្រី ឬ អ្នកដទៃបានឡើយ ។

គ. **ការសម្ងាត់របស់តុលាការ និងវិជ្ជាជីវៈ** ៖ តាមរយៈការចូលរួមរបស់កូនក្តីខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទាំងមេធាវីនិងកូនក្តីរបស់ខ្លួនអាចមានសិទ្ធិសុំពិនិត្យព័ត៌មានសម្ងាត់ ដែលមាននៅក្នុងសំណុំរឿង ។ ប៉ុន្តែមានតែចៅក្រមរបស់អង្គជំនុំជម្រះវិសាមញ្ញប៉ុណ្ណោះ ដែលអាចសម្រេចដាក់ព័ត៌មានទាំងនោះសម្រាប់ផ្សព្វផ្សាយជាសាធារណៈ ។ លោក/លោកស្រីជាប់នូវកាតព្វកិច្ចមិនឲ្យផ្សព្វផ្សាយព័ត៌មានសម្ងាត់ជាសាធារណៈនេះទេ ។

ឃ. **ការដាក់ឯកសារ** ៖ ឯក សារផ្លូវការទាំងអស់ត្រូវដាក់តាមរយៈមន្ត្រីគ្រប់គ្រងសំណុំរឿង ដូចមានចែងក្នុងសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ។ លោក/លោកស្រីនឹងទទួលបាននូវការជូន

ដំណឹងជាទម្រង់អេឡិចត្រូនិកអំពីឯកសារដែលបានដាក់នៅក្នុងសំណុំរឿង ហេតុដូច្នេះលោក/លោកស្រីត្រូវផ្តល់នូវអ៊ីមែល(E-mail) របស់ខ្លួនទៅក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង ។ យើងអាចផ្តល់នូវការជូនដំណឹងជាទម្រង់ក្រដាស ប្រសិនបើអ្នកមិនអាចប្រើប្រាស់អ៊ីមែលបាន ។

ភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

និល ណុន